ក

# មាតិកា

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 6 ខែ 06 ឆ្នាំ 2003

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


០១-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣០៨ ស្តីពីការតែងតាំងឯកឧត្តម **សុខ កុសល** ជាឧបការីប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ២៤៦៧

០១-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣០៩ ស្តីពីការតែងតាំងឯកឧត្តម **ចាន់ លេក្ខា** បច្ចុប្បន្នអគ្គទីក្រោស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំងជានាយក ផ្ទះខ្មែរ (MAISON DU CAMBODGE) នៅសាធារណរដ្ឋបារាំង ២៤៦៨

០១-៩-២០០១ -ព្រះរាជក្រឹត្យនស/រកត/០៩០១/៣១០ស្តីពីការ បំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **ជា ចាន់តូ** ២៤៦៩

០១-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣១១ ស្តីពីការ បំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តម **អេង ថ្លាយសាន** ២៤៧០

០១-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣១២ ស្តីពីការតែងតាំង ឯកឧត្តម **ចាន់ ពន** ជាប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកទេស នៃរាជបណ្ឌិតសភាកម្ពុជា ២៤៧១

០១-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣១៣ ស្តីពីការតែងតាំង ឯកឧត្តម **លី ស៊ូ** ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអភិបាលរងរាជធានីភ្នំពេញ ២៤៧២

០១-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣១៤ ស្តីពីការតម្លើងឋានន្តរសក្តិជូននាយនគរ បាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ២៤៧៣

០៣-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣១៨ ស្តីពីការតម្លើងឋានន្តរសក្តិ ថ្នាក់នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ជូនឯកឧត្តមឧត្តមសេនីយ៍ឯក **ប៉ុល សារឿន** ២៤៧៥

០៣-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣១៩ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ឯកជូនឥស្សរជនជាន់ខ្ពស់នៃក្រសួងការពារជាតិចំនួន ០២ រូប ២៤៧៦

០៤-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣២០ ស្តីពីការតែងតាំង ឯកឧត្តម **ឡា ណារ៉ាត** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាសមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ ពត៌មានវិទ្យាជំនួស ឯកឧត្តម **ផាន់ គីន** ២៤៧៧

០៧-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣២១ ស្តីពីការតែងតាំងឯកឧត្តម **ស៊ុំ ឈុំប៊ុន** ជាអគ្គលេខាធិការរងនៃរាជបណ្ឌិតសភាកម្ពុជា ២៤៧៨

០៧-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣២២ ស្តីពីការតែងតាំងឯកឧត្តម **ហួត ទុទ្ធី** ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាបន្ថែមលើមុខងារបច្ចុប្បន្ន ២៤៧៩

០៨-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣២៣ ស្តីពីការបញ្ឈប់ឯកឧត្តម **ឈឹម សៀកឡេង** ពីតំណែងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- តម្លើងឋានន្តរសក្តិជូនឯកឧត្តម **វ៉េង សិរីវុឌ្ឍ** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ជាទេសរដ្ឋមន្ត្រី ២៤៨០


## II- រាជរដ្ឋាភិបាល

### ១_ អនុក្រឹត្យ


០៣-៩-២០០១ - អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៤៨១

០៥-៩-២០០១ - អនុក្រឹត្យលេខ ៨៨ អនក្រ.បក ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលនៅក្នុងក្របខ័ណ្ឌថ្មី ២៤៨៣

០៧-៩-២០០១ - អនុក្រឹត្យលេខ ៨៩ អនក្រ.បក ស្តីពីកាបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ២៥០១

០៧-៩០២០០១ - អនុក្រឹត្យលេខ ៩០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៥០៤

៣១-៨-២០០១ - អនុក្រឹត្យលេខ ៤០១ អនក្រ.តត ស្តីពីការតែងតាំងនិងផ្ទេរភារកិច្ចនាយនគរបាលជាតិ ២៥០៦

០៣-៩-២០០១ - អនុក្រឹត្យលេខ ៤០២ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្ម របស់ មន្ត្រីការទូត ២៥០៨

០៣-៩-២០០១ - អនុក្រឹត្យលេខ ៤០៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៥០៩

០៦-៩-២០០១ - អនុក្រឹត្យលេខ ៤០៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៥១០

០៦-៩-២០០១ - អនុក្រឹត្យលេខ ៤០៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ ថ្នាក់វរសេនីយ៍ ឯកចំពោះសពៈ

១- វរសេនីយ៍ទោ **គង់ សំអឿន**

២_ វរសេនីយ៍ទោ **យូ ស៊ុគន**

៣- វរសេនីយ៍ទោ **ភ្លឹម ភូឡា** ២៥១២

០៧-៩-២០០១ - អនុក្រឹត្យលេខ ៤០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៥១៣

០៧-៩-២០០១ - អនុក្រឹត្យលេខ ៤០៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៥១៤

០៧-៩០២០០១ - អនុក្រឹត្យលេខ ៤០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៥១៦


### ២_សេចក្តីជូនដំណឹង


០៥-៩-២០០១ - សេចក្តីជូនដំណឹងលេខ ៤២ សជណ ២៥១៧

# គ

## III- ការងារបណ្តាក្រសួង


### ១_ ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

០៥-៩-២០០១ - ប្រកាសលេខ ៩៦៦ សហវ ស្តីការកំណត់ពន្ធនាំចូលជាបន្ទុករបស់រដ្ឋ លើការនាំចូលទំនិញជាវត្ថុធាតុដើមសំរាប់ផលិតឱសថ ២៥១៩

### ២_ ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

៣១-៨-២០០១ - ប្រកាសលេខ ៣៨៤ ប្រក.សក.បច ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ២៥២១

### ៣_ ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

០៣-៩-២០០១ - ប្រកាសលេខ ២១៤ បទ.ប្រក ស្តីពីការតម្លើងកាំប្រាក់បៀវត្សជូនមន្ត្រីបុគ្គលិករាជការ ២៥២៣

### ៤_ ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

០៣-៩-២០០១ - ប្រកាសលេខ ២៣៤/០១ ពម. ប្រក ស្តីពីការអនុញ្ញាតឱ្យអ្នកស្រី SIEW NYOKE CHOW ជំនួសលោក **ឆិត ខួន** បន្តបើកអាជីវកម្មរោងពុម្ពឈ្មោះ CAMBODIA SIN CHEW DAILY ២៥២៥

០៣-៩-២០០១ - ប្រកាសលេខ ២៣៥/០១ ពម. ប្រក ស្តីពីការអនុញ្ញាតឱ្យសារពតិមាននារីខ្មែរ ដំណើការបោះពុម្ពចែកផ្សាយដោយមាន កញ្ញា **ឃុន រដ្ឋា** ជាចាងហ្វាងការផ្សាយ ២៥២៦

០៤-៩-២០០១ - ប្រកាសលេខ ២៣៧/០១ ពម. ប្រក ស្តីពីការអនុញ្ញាតឱ្យទស្សនាវដ្តី កម្ពុជាមរតក ដំណើការបោះពុម្ពចែកផ្សាយដោយមាន លោក **ប៉ុក ចន្ទតារា** ជាចាងហ្វាងការផ្សាយ ២៥២៧

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣០៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ៥៨៧ រស ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១
- យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម សុខ កុសល ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

ធ្វើនៅភ្នំពេញ ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០១

លេខៈ ៧១៨ ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាន់ តាន់

# ព្រះរាជក្រឹត្យ

នស/រកត ០៩០១/៣០៩

យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម ចាន់ លេក្ខា បច្ចុប្បន្នអគ្គទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង ជានាយកផ្ទះខ្មែរ ( Maison du Cambodge ) នៅសាធារណរដ្ឋបារាំង មានឋានៈស្មើ អគ្គរាជទូត ។

**មាត្រា ២** : ក្នុងរយៈពេលរង់ចាំផ្ទះខ្មែរជួសជុលរួច ឯកឧត្តម ចាន់ លេក្ខា ត្រូវធ្វើការបន្តទៀត នៅស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង ក្នុងឋានៈជាអគ្គទីប្រឹក្សាស្ថានទូតដដែល ។

**មាត្រា ៣** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ៤០០ ច.ល

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០១

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០១

...រាជរដ្ឋាភិបាល

...តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣១០

យើង

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ក្នុងការបំរើប្រទេសជាតិ លើការងារអភិវឌ្ឍន៍វិស័យធនាគារនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

លេខៈ ២០១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣១១

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនឯកឧត្តម អេង ថ្វាយសាន ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ក្នុងការបំរើប្រទេសជាតិលើការងារអភិវឌ្ឍន៍វិស័យធនាគារនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ២០២ ច.ល

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០១

ដើម្បីចម្លងចែកចាយ

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឧកញ៉ា ស៊ាន

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣១២

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ចាន់ ពន ជាប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកទេស នៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ២០៣ ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣១៣

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម លី ស៊ូ ជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរង រាជធានីភ្នំពេញ ។

មាត្រា ២ : រាល់បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ២០៤ ច.ល

បានឃើញនិងបម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០១

# ព្រះរាជក្រឹត្យ

នស / រកត /០៩០១ /៣១៤

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានខាងក្រោម ÷

**ក- តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ ជូន :**

១- ឧត្តមសេនីយ៍ត្រី ម៉ៅ ច័ន្ទតារា អត្តលេខ ០០២៣ ប្រធានសេនាធិការដ្ឋាន នៃក្រសួងមហាផ្ទៃ

២- ឧត្តមសេនីយ៍ត្រី ម៉ៅ ប៊ុនណារិន អត្តលេខ ០០៣៦ ប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងមហាផ្ទៃ

៣- ឧត្តមសេនីយ៍ត្រី ស៊ុខ ផល អត្តលេខ ០០៩១ ប្រធាននាយកដ្ឋានពតិមានទូទៅ នៃក្រសួងមហាផ្ទៃ

៤- ឧត្តមសេនីយ៍ត្រី ហ៊ីង ធន អត្តលេខ ០០៣០ ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន នៃក្រសួងមហាផ្ទៃ

៥- ឧត្តមសេនីយ៍ត្រី ចាន់ អ៊ិន អត្តលេខ ០០២៤ ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក នៃក្រសួងមហាផ្ទៃ

៦- ឧត្តមសេនីយ៍ត្រី ស៊ឹម សុផល អត្តលេខ ០០៤៣ ប្រធាននាយកដ្ឋានអង្គរក្ស នៃក្រសួងមហាផ្ទៃ

៧- ឧត្តមសេនីយ៍ត្រី ឧុល គឿន អត្តលេខ ០០៣៧ ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ
៨- ឧត្តមសេនីយ៍ត្រី ចក់ ឡេង អត្តលេខ ០០៨៥ ប្រធាននាយកដ្ឋានភស្តុភារនិងសំភារៈបច្ចេកទេស នៃក្រសួងមហាផ្ទៃ
៩- ឧត្តមសេនីយ៍ត្រី ប៉ូ បិផា អត្តលេខ ០០៦៩ ប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ នៃក្រសួងមហាផ្ទៃ
១០- ឧត្តមសេនីយ៍ត្រី ផ្លុង គីមភុន អត្តលេខ ០០៦៤ អភិបាលរងទី ១ ខេត្តកោះកុង
១១- ឧត្តមសេនីយ៍ត្រី ថាវ គីមឡុង អត្តលេខ ០១៣៩ អភិបាលរងទី ១ ខេត្តកំពង់ចាម

ខ - តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូន :

១- វរសេនីយ៍ឯក សួស អង្គារ អត្តលេខ ០១៣២ អនុប្រធានទី ១ នាយកដ្ឋាននគរបាលរដ្ឋបាល នៃក្រសួងមហាផ្ទៃ
២- វរសេនីយ៍ឯក មៀច សុផាន់ណា អត្តលេខ ០២៩២ អនុប្រធាននាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ
៣- វរសេនីយ៍ឯក យ៉ែម គឿង អត្តលេខ ០១១១ អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ នៃក្រសួងមហាផ្ទៃ
៤- វរសេនីយ៍ឯក សាយ ឡោ អត្តលេខ ០២៨៤ ប្រធាននាយកដ្ឋានសុខាភិបាល នៃក្រសួងមហាផ្ទៃ
៥- វរសេនីយ៍ឯក សុខ សួស៊ី អត្តលេខ ០៣៧៦ នាយករងខុទ្ទកាល័យ នៃក្រសួងមហាផ្ទៃ
៦- វរសេនីយ៍ឯក ថាវ គីមបោ អត្តលេខ ០២៤៣ ប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ នៃក្រសួងមហាផ្ទៃ
៧- វរសេនីយ៍ឯក ហួរ ឡាយ អត្តលេខ ០៣៩៧ អនុប្រធានទី១នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នៃក្រសួងមហាផ្ទៃ
៨- វរសេនីយ៍ឯក សួ តាំងឆាយ អត្តលេខ ០៧២៧ អនុប្រធានទី ១ នាយកដ្ឋានបុគ្គលិក នៃក្រសួងមហាផ្ទៃ

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ២០៥ ច.ល

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាយ៉ុ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣១៨

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសំរួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១** : តម្លើងឋានន្តរសក្តិថ្នាក់នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ជូនឯកឧត្តមឧត្តមសេនីយ៍ឯក ប៉ុល សារឿន អត្តលេខ ០០០០១៧ អគ្គមេបញ្ជាការរង និងជានាយសេនាធិការកំពុះ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០១*

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

**ហ៊ុន សែន**

លេខ: ៧១២ ច.ល

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០០១

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**ស៊ុំ ស៊ារិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣១៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

មាត្រា ១ : តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ឯក ជូនឥស្សរជនជាន់ខ្ពស់ នៃក្រសួងការពារជាតិ ដូចមានខាងក្រោម ÷

១- ឯកឧត្តមឧត្តមសេនីយ៍ទោ ឡាយ អ៊ុំពិសិទ្ធ អត្តលេខ ០០០២៣៥ អនុរដ្ឋលេខាធិការក្រសួងការពារជាតិ

២- ឯកឧត្តមឧត្តមសេនីយ៍ទោ ជុំ សម្បុន អត្តលេខ ០០០២៤១ អនុរដ្ឋលេខាធិការក្រសួងការពារជាតិ

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០១

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ២១៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឆន ស៊ាន**

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣២០

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ឡុង ណារ៉េត អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ជំនួសឯកឧត្តម ផាវ៉ន តិន បច្ចុប្បន្នកំពុងសំរាកព្យាបាលជំងឺ នៅសាធារណរដ្ឋបារាំង ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០១

លេខ ៣២៥ ច.ល

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ណារិន្ទ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣២១

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ស៊ី ឈុំប៊ុន ជាអគ្គលេខាធិការរង នៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើអគ្គនាយក ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[signature]

សុខ ចាន់

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០១*

បណ្ណសាររដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣២២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០១

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ហួត ទុន្នី ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៧២៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០១

នស/រកត/០៩០១/៣២៣

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១** : បញ្ឈប់ឯកឧត្តម **ឈឹម សៀកឡេង** ពីតំណែងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២** : ដំឡើងឋានន្តរសក្តិជូនឯកឧត្តម **ម៉េង សាំខុឡ** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ជាទេសរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ៣** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម **ឈឹម សៀកឡេង** ឯកឧត្តម **ម៉េង សាំខុឡ** ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៧៧៥ ច.ល

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០០១ រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០១

បានឃើញថ្លែងអំណែក

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ឆាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានថវិកា ចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ៥២០ លានរៀល ( ប្រាំរយម្ភៃលានរៀលគត់ ) ពីជំពូក ១២ (ឧបត្ថម្ភថវិកា ឃុំ សង្កាត់ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បើកវគ្គបណ្តុះបណ្តាលស្មៀនឃុំ សង្កាត់ ចំនួន ២៤ វគ្គ ដែលមានសិក្ខាកាមចំនួន ៨៥៨ នាក់ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៩៨...អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## គោលការណ៍ សមាហរណកម្ម មន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០០ ស្ដីពីការបង្កើតគណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី

-តាមការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០១

## សំរេច

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះ កំណត់គោលការណ៍សំរាប់ធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ក្នុងក្របខ័ណ្ឌរដ្ឋបច្ចុប្បន្ន ដែលកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដនៅថ្នាក់កណ្តាលនិងខេត្ត ក្រុង ផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មី ស្របតាមលក្ខន្តិកៈដោយឡែករបស់ក្របខ័ណ្ឌនីមួយៗ ។

# ជំពូកទី ២

# គោលការណ៍សមាហរណកម្មតាមមុខតំណែង

**មាត្រា២ ._**

មន្ត្រីរាជការដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ គឺមន្ត្រីទាំងឡាយ ដែលកំពុងកាន់មុខតំណែងពិតប្រាកដនៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នមាន ÷

**ក/ឋានន្តរស័ក្តិឧត្តមមន្ត្រី**

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នៃក្រសួង ស្ថាប័ន

-ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

**ខ/ឋានន្តរស័ក្តិវរៈមន្ត្រី**

-អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ប្រធាននាយកដ្ឋាន អធិការ នៃក្រសួង ស្ថាប័ន

-អភិបាលរងខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

**គ/ឋានន្តរស័ក្តិអនុមន្ត្រី**

-អនុប្រធាននាយកដ្ឋាន អធិការរង នៃក្រសួង ស្ថាប័ន

-ប្រធានមន្ទីរខេត្ត ក្រុង

-អភិបាលស្រុក ខ័ណ្ឌ

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

មាត្រា៣ .-

ការផ្ទេរមន្ត្រីបញ្ចូលទៅក្នុងថ្នាក់ នៃឋានន្តរស័ក្តិនីមួយៗរបស់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

មាត្រា៤ .-

មន្ត្រីរដ្ឋបាលដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការសំរាប់អន្តរក្រសួង និងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ គឺមន្ត្រីទាំងឡាយដែលកំពុងកាន់មុខតំណែងពិតប្រាកដនៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធក្រសួង ស្ថាប័នមាន ÷

ក/ឋានន្តរស័ក្តិនាយក្រមការ

-ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល

-អនុប្រធានមន្ទីរនៅខេត្ត ក្រុង

-អភិបាលរងស្រុក ខ័ណ្ឌ

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

ខ/ឋានន្តរស័ក្តិក្រមការដើមខ្សែ

-អនុប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល

-ប្រធានការិយាល័យ នៃមន្ទីរនៅខេត្ត ក្រុង សាលាខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

គ/ឋានន្តរស័ក្តិក្រមការ

-អនុប្រធានការិយាល័យ នៃមន្ទីរខេត្ត ក្រុង សាលាខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

មាត្រា៥ .-

ការផ្ទេរមន្ត្រីបញ្ចូលទៅក្នុងថ្នាក់ នៃឋានន្តរស័ក្តិនីមួយៗ របស់ក្របខ័ណ្ឌមន្ត្រីក្រមការសំរាប់អន្តរក្រសួង និងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

មាត្រា៦ .-

មន្ត្រីគ្រប់គ្រងរដ្ឋបាល និងមន្ត្រីរដ្ឋបាលជាន់ខ្ពស់ដែលមានចែងក្នុងមាត្រា ២ បើបៀវត្សបច្ចុប្បន្នស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយមួយថ្នាក់ និងក្នុងកាំទី ៣ ត្រូវបន្ថែមអោយពីរថ្នាក់ ។

មន្ត្រីក្រមការសំរាប់អន្តរក្រសួង និងមន្ត្រីក្រមការក្រសួងមហាផ្ទៃ ដែលមានចែងក្នុងមាត្រា ៤ បើបៀវត្សបច្ចុប្បន្នស្ថិតក្នុងកាំទី ២ ត្រូវចាត់បញ្ចូលទៅក្នុងថ្នាក់លើបន្ទាប់មួយថ្នាក់ ។

ចំពោះមន្ត្រីដែលមានអតីតភាពការងារតិចជាង ៨ ឆ្នាំ កំពុងកាន់មុខតំណែង ហើយដែលត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ២ ត្រូវដាក់អោយស្ថិតនៅក្នុងថ្នាក់លេខ ១០ ទោះបីបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ក៏ដោយ ។

ចំពោះមន្ត្រីដែលមានអតីតភាពការងារតិចជាង ១៦ ឆ្នាំ កំពុងកាន់មុខតំណែង ហើយដែលត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ១ ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ ៦ ទោះបីបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ក៏ដោយ ។

**មាត្រា៧ ._**

មន្ត្រីរាជការស៊ីវិលដែលកំពុងបំរើការងារនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីការទូតក្នុងឋានន្តរស័ក្តិស្របនឹងឋានន្តរស័ក្តិនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាល ។

## ជំពូកទី ៣

## គោលការណ៍សមាហរណកម្មតាមប្រភេទកាំបៀវត្ស

**មាត្រា៨ ._**

មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌរដ្ឋ ក្រៅពីមន្ត្រីដែលត្រូវធ្វើសមាហរណកម្មទៅតាមគោលការណ៍មុខតំណែងខាងលើ ត្រូវធ្វើសមាហរណកម្មតាមប្រភេទកាំបៀវត្សបញ្ចូលក្នុងក្របខ័ណ្ឌថ្មីដូចខាងក្រោម ÷

-ខ I បញ្ចូលទៅក្នុងក្របខ័ណ្ឌប្រភេទ **ក**

-ខ II បញ្ចូលទៅក្នុងក្របខ័ណ្ឌប្រភេទ **ខ**

-ខ III , គ I និង ក II.១១ បញ្ចូលទៅក្នុងក្របខ័ណ្ឌប្រភេទ **គ**

-ខ IV , គ II , គ III និង គ IV បញ្ចូលទៅក្នុងក្របខ័ណ្ឌប្រភេទ **ឃ**

ការរៀបបញ្ចូលទៅក្នុងថ្នាក់នីមួយៗនៃក្របខ័ណ្ឌថ្មី ត្រូវបានកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ ។

**មាត្រា៩ ._**

មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌរដ្ឋដែលកាំបៀវត្សបច្ចុប្បន្នស្ថិតក្នុងកាំទី ៦ នៃប្រភេទ ខ I , ខ II , ខ III , ខ IV និង គ I , គ II , គ III , គ IV ហើយមានរយៈពេលចាប់ពី ៣ ឆ្នាំឡើងទៅ ត្រូវរៀបបញ្ចូលទៅក្នុងថ្នាក់ថ្មីដោយគិតរយៈពេល ៣ ឆ្នាំ សំរាប់មួយថ្នាក់ ។

**មាត្រា១០ ._**

ក្រៅពីក្របខ័ណ្ឌមន្ត្រីដែលលក្ខន្តិកៈដោយឡែកកំណត់ ការឡើងឋានន្តរស័ក្តិផ្អែកតាមមុខតំណែងដែលទំនេរ មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌរដ្ឋដែលបានរៀបបញ្ចូលទៅក្នុងថ្នាក់លេខ ១១ ឡើងទៅ អាចជ្រើសរើសយកចំនួនអតិបរមាស្មើនឹង ៣០ ភាគរយ លើចំនួនរួមនៃក្របខ័ណ្ឌ បញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ២ ដោយដាក់ថ្នាក់លេខ

១១ នៃឋានន្តរស័ក្តិទី ៣ បញ្ចូលទៅក្នុងថ្នាក់លេខ ១០ នៃឋានន្តរស័ក្តិទី ២ ហើយរៀបតាមលំដាប់ថ្នាក់ជាបន្តបន្ទាប់ ។

**មាត្រា១១ ._**

មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌរដ្ឋដូចមានចែងក្នុងមាត្រា ៨ និងមាត្រា ១០ ដែលបានបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ២ ហើយស្ថិតនៅក្នុងថ្នាក់លេខ ៧ ឡើងទៅ អាចជ្រើសរើសយកចំនួនអតិបរមាស្មើនឹង ៥ ភាគរយលើចំនួនរួមនៃក្របខ័ណ្ឌនីមួយៗ បញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ១ ដោយដាក់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិទី ២ បញ្ចូលទៅក្នុងថ្នាក់លេខ ៦ នៃឋានន្តរស័ក្តិទី ១ ហើយរៀបតាមលំដាប់ថ្នាក់ជាបន្តបន្ទាប់ ។

ក្នុងករណីដែលការជ្រើសរើសយកអតិបរមា ៥ ភាគរយ បញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ១ នេះ មិនបានតាមចំនួនសមស្រប អាចជ្រើសរើសបន្ថែមយកមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិទី ២ ហើយមានអតីតភាពការងារចាប់ពី ១៦ ឆ្នាំឡើងទៅ ហើយមានកាំប្រៀវត្សរ៍បច្ចុប្បន្នខ្ពស់ជាងគេ ។

**មាត្រា១២ ._**

ការជ្រើសរើសបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ២ និងទី ១ ដូចមានចែងក្នុងមាត្រា ១០ និងមាត្រា ១១ ខាងលើ ត្រូវយកចិត្តទុកដាក់ចំពោះមន្ត្រីដែលមានសញ្ញាប័ត្រខ្ពស់ និងអ្នកដែលមានសមត្ថភាពបទពិសោធន៍ក្នុងការបំពេញការងារមានគុណសម្បត្តិខ្ពស់ ។

## ជំពូកទី ៤

## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៣ ._**

មន្ត្រីដែលកំពុងកាន់មុខតំណែងដូចមានចែងក្នុងមាត្រា ៤ ហើយមានបរិញ្ញាប័ត្រ ឬមានសញ្ញាប័ត្រសមមូល ត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ដោយដាក់ក្នុងឋានន្តរស័ក្តិអនុមន្ត្រី ។

មន្ត្រីដែលកំពុងកាន់មុខតំណែងពិតប្រាកដដូចមានចែងក្នុងមាត្រា ២ និងមាត្រា ៤ ខាងលើ ហើយមានសញ្ញាប័ត្រជំនាញបច្ចេកទេសផ្សេងៗ អាចសុំស្ថិតនៅក្នុងក្របខ័ណ្ឌបច្ចេកទេស តាមការកំណត់របស់លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌនីមួយៗ ។

**មាត្រា១៤ ._**

មន្ត្រីដែលកំពុងបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ ហើយមានកំរិតសញ្ញាប័ត្រខ្ពស់ជាងប្រភេទកាំប្រៀវត្សរ៍ ឬខ្ពស់ជាងមុខតំណែងរបស់ខ្លួន នៅពេលធ្វើសមាហរណកម្មត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីទៅតាមកំរិតសញ្ញាប័ត្រ ។

**មាត្រា១៥ ._**

ក្រៅពីការធ្វើសមាហរណកម្មតាមមុខតំណែងដែលមានចែងក្នុងមាត្រា ២ ខាងលើ មន្ត្រីរាជការក្របខ័ណ្ឌរដ្ឋ ត្រូវធ្វើសមាហរណកម្ម ផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីតាមគោលការណ៍ដូចខាងក្រោម ÷

-ចំពោះមន្ត្រីដឹកនាំដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក II.១ , ក II.២ , ក II.៣ ត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ទៅក្នុងថ្នាក់លេខ ១ នៃឋានន្តរស័ក្តិឧត្តមមន្ត្រី ។

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក II.៤.១ , ក II.៤.២ , ក II.៤.៣ និង ក II.៥.១ , ក II.៥.២ ដែលតែងតាំងដោយព្រះរាជក្រឹត្យ ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ។

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក II.៦.១ , ក II.៦.២ , និង ក II.៥.១ , ក II.៥.២ ដែលតែងតាំងដោយអនុក្រឹត្យ ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី ។

-ចំពោះមន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក II.៧.១ និង ក II.៧.២ ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី ។

ការដាក់បញ្ចូលទៅក្នុងថ្នាក់ នៃឋានន្តរស័ក្តិនីមួយៗខាងលើ ត្រូវគិតតាមការកំណត់នៃអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ និងគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

√ **មាត្រា១៦ ._**

ចំពោះមន្ត្រីថ្នាក់មន្ត្រីជាន់ខ្ពស់ជំនាន់ទី១ និងជំនាន់ទី២នៃសាលាភូមិន្ទរដ្ឋបាល ដែលបានទទួលជោគជ័យក្នុងការប្រឡងចេញ ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១១ ឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ឬក្របខ័ណ្ឌប្រភេទ ក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំពោះមន្ត្រីថ្នាក់មធ្យមជំនាន់ទី១ និងជំនាន់ទី២នៃសាលាភូមិន្ទរដ្ឋបាល ដែលបានទទួលជោគជ័យក្នុងការប្រឡងចេញ ត្រូវបានទទួលអត្ថប្រយោជន៍ដូចខាងក្រោម ÷

-មន្ត្រីដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិបូក២ នៅពេលប្រឡងចូលត្រូវបញ្ចូលទៅក្នុងថ្នាក់ លេខ ១៣ ឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ។

-មន្ត្រីដែលមានបរិញ្ញាប័ត្រ ឬសញ្ញាបត្រ័សមមូលនៅពេលប្រឡងចូលត្រូវបញ្ចូលទៅក្នុងថ្នាក់ លេខ ១២ ឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ។

មាត្រា១៧ ._

មន្ត្រីរាជការស៊ីវិលបច្ចុប្បន្នក្នុងក្របខ័ណ្ឌរដ្ឋដែលមានកាំបៀវត្សក្នុងប្រភេទ ខ I , ខ II , ខ III , ខ IV និង គ I , គ II , គ III , គ IV អាចធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលប្រភេទ ក.ខ.គ.ឃ បាន តាមល័ក្ខខ័ណ្ឌកំណត់ដូចមានចែងក្នុងអនុក្រឹត្យនេះ ។ មន្ត្រីទាំងនោះ រួមមានមន្ត្រីទាំងឡាយដែលកំពុងបំពេញការងារនៅ ÷

ក/រដ្ឋបាលសំរាប់អន្តរក្រសួង

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងព្រះបរមរាជវាំង

-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា - ព្រឹទ្ធសភា និងអធិការកិច្ច

-ក្រសួងធម្មការ និងសាសនា លើកលែងគ្រូបង្រៀនដែលត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌគ្រូបង្រៀន នៃក្រសួងអប់រំ យុវជន និងកីឡា

-អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការដ្ឋាន អធិការដ្ឋាន នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានផែនការ នៃក្រសួងស្ថាប័នដទៃក្រៅពីក្រសួងស្ថាប័នដែលរៀបរាប់ខាងលើ និងមន្ត្រីដែលធ្វើការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ផែនការ នៅថ្នាក់កណ្តាល និងនៅមន្ទីរខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ។

ខ/រដ្ឋបាលមហាផ្ទៃ

-ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលស៊ីវិល ។

មាត្រា១៨ ._

ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតគណៈកម្មការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលមួយ ដឹកនាំដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដែលចាំបាច់ត្រូវមានអគ្គនាយកដ្ឋានរដ្ឋបាល ឬនាយកដ្ឋានរដ្ឋបាលបុគ្គលិក នាយកដ្ឋានបុគ្គលិក ឬការិយាល័យបុគ្គលិក ជាអ្នករៀបចំឯកសារសំរាប់ដាក់ជូនគណៈកម្មការនេះ ។

រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈមានភារកិច្ចណែនាំអំពីនីតិវិធី នៃការអនុវត្តន៍គោលការណ៍ធ្វើសមាហរណកម្មនេះ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា១៩ .–**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា២០ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា២១.–**

អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២០

-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០១

# គោលការណ៍

## សមាហរណកម្មមន្ត្រីរដ្ឋបាលបច្ចុប្បន្ន ផ្ទេរបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងមន្ត្រីការទូតជាន់ខ្ពស់

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលនៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី មាន ៖**

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នៃក្រសួង ស្ថាប័ន

-ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

-មន្ត្រីរាជការស៊ីវិលដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក.៤.១ , ក.៤.២ និង ក.៤.៣

-មន្ត្រីរាជការស៊ីវិលដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក.៥ ដែលតែងតាំងដោយព្រះរាជក្រឹត្យ ។

| ឋានន្តរស័ក្តិ ឧត្តមមន្ត្រី | **អតីតភាពបំរើការងាររដ្ឋ** |
|---|---|
| **ថ្នាក់លេខ ១** | |
| **ថ្នាក់លេខ ២** | |
| **ថ្នាក់លេខ ៣** | ២៥ ឆ្នាំ ឡើង |
| **ថ្នាក់លេខ ៤** | ២២ - ២៥ ឆ្នាំ |
| **ថ្នាក់លេខ ៥** | ១៩ - ២២ ឆ្នាំ |
| **ថ្នាក់លេខ ៦** | ១៦ - ១៩ ឆ្នាំ |

**កំណត់សំគាល់ :**

-ក្នុងថ្នាក់នីមួយៗ បើប្រៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ ថ្នាក់ និងក្នុងកាំទី ៣ ត្រូវបន្ថែមអោយ ២ ថ្នាក់

-មន្ត្រីដែលមានអតីតភាពការងារតិចជាង ១៦ ឆ្នាំ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ ៦ ទោះបីប្រៀវត្សស្ថិតនៅក្នុងកាំទី ២ ក៏ដោយ ។

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី មាន ៖**

-អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ប្រធាននាយកដ្ឋាន អធិការ នៃក្រសួង ស្ថាប័ន

-អភិបាលរង ខេត្ត ក្រុង

-ថ្នាក់ស្មើ នឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

-មន្ត្រីរាជការស៊ីវិលដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ក II.៦.១ , ក II.៦.២ និង ក II.៥.១ , ក II.៥.២ ដែលតែងតាំងដោយអនុក្រឹត្យ ។

| ឋានន្តរស័ក្តិ វរៈមន្ត្រី | អតីតភាពបំរើការងាររដ្ឋ | |
|---|---|---|
| | ប្រភេទកាំបៀវត្សបច្ចុប្បន្ន ក II.៦ | ប្រភេទកាំបៀវត្សបច្ចុប្បន្ន ក II.៥ ដែលតែងតាំងដោយអនុក្រឹត្យ |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | ២៣ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៥ | ២៣ ឆ្នាំ ឡើង | ២០ - ២៣ ឆ្នាំ |
| ថ្នាក់លេខ ៦ | ២០ - ២៣ ឆ្នាំ | ១៧ - ២០ ឆ្នាំ |
| ថ្នាក់លេខ ៧ | ១៧ - ២០ ឆ្នាំ | ១៤ - ១៧ ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៤ - ១៧ ឆ្នាំ | ១១ - ១៤ ឆ្នាំ |
| ថ្នាក់លេខ ៩ | ១១ - ១៤ ឆ្នាំ | ៨ - ១១ ឆ្នាំ |
| ថ្នាក់លេខ ១០ | ៨ - ១១ ឆ្នាំ | |

**កំណត់សំគាល់ :**

-ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ថ្នាក់

-មន្ត្រីដែលមានអតីតភាពការងារតិចជាង ៨ ឆ្នាំ ក្នុងឋានន្តរស័ក្តិវរៈមន្ត្រី ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ ១០ ទោះបីបៀវត្សស្ថិតក្នុងកាំទី ២ ក៏ដោយ

-មន្ត្រីដែលមានប្រភេទកាំបៀវត្ស ក II.៥.១ ត្រូវរៀបបញ្ចូលដោយគិតពីថ្នាក់លេខ ៩ នៃឋានន្តរស័ក្តិវរៈមន្ត្រី ជាចំនុចចាប់ផ្តើម ។

មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី មាន ÷

-អនុប្រធាននាយកដ្ឋាន អធិការរង ប្រធានមន្ទីរខេត្តក្រុង

-អភិបាលស្រុក ខណ្ឌ

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅ ក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

-មន្ត្រីរាជការស៊ីវិលដែលមានប្រភេទកាំប្រៀវត្សរ៍បច្ចុប្បន្ន ក II.៧.១ , ក II.៧.២ ។

| ឋានន្តរស័ក្តិ អនុមន្ត្រី | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | |
| ថ្នាក់លេខ ៦ | ២៤ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៧ | ២១ - ២៤ ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៨ - ២១ ឆ្នាំ |
| ថ្នាក់លេខ ៩ | ១៥ - ១៨ ឆ្នាំ |
| ថ្នាក់លេខ ១០ | ១២ - ១៥ ឆ្នាំ |
| ថ្នាក់លេខ ១១ | ៩ - ១២ ឆ្នាំ |
| ថ្នាក់លេខ ១២ | ៦ - ៩ ឆ្នាំ |
| ថ្នាក់លេខ ១៣ | ៣ - ៦ ឆ្នាំ |
| ថ្នាក់លេខ ១៤ | ក្រោម ៣ ឆ្នាំ |

កំណត់សំគាល់ :

-ក្នុងថ្នាក់នីមួយៗ បើប្រៀវត្សរ៍មន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ថ្នាក់ ។

ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០១

# គោលការណ៍
# សមាហរណកម្មមន្ត្រីរដ្ឋបាលបច្ចុប្បន្ន
# ចូលក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ មាន ÷**

-ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល អនុប្រធានមន្ទីរនៅខេត្ត ក្រុង

-អភិបាលរងស្រុក ខណ្ឌ

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

| ឋានន្តរស័ក្តិ នាយក្រមការ | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | ២៥ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៤ | ២២ - ២៥ ឆ្នាំ |
| ថ្នាក់លេខ ៥ | ១៩ - ២២ ឆ្នាំ |
| ថ្នាក់លេខ ៦ | ១៦ - ១៩ ឆ្នាំ |

**កំណត់សំគាល់ :**

-ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ ថ្នាក់

-មន្ត្រីដែលមានអតីតភាពការងារតិចជាង ១៦ ឆ្នាំ ក្នុងឋានន្តរស័ក្តិនាយក្រមការ ត្រូវដាក់អោយស្ថិតក្នុងថ្នាក់លេខ ៦ ទោះបីបៀវត្សស្ថិតក្នុងកាំទី ២ ក៏ដោយ ។

មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ មាន ៖

-អនុប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល

-ប្រធានការិយាល័យ នៃមន្ទីរនៅខេត្តក្រុង សាលាខេត្តក្រុង

-ថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

| ឋានន្តរស័ក្តិ ក្រមការដើមខ្សែ | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | ២៣ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៦ | ២០ - ២៣ ឆ្នាំ |
| ថ្នាក់លេខ ៧ | ១៧ - ២០ ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៤ - ១៧ ឆ្នាំ |
| ថ្នាក់លេខ ៩ | ១១ - ១៤ ឆ្នាំ |
| ថ្នាក់លេខ ១០ | ៨ - ១១ ឆ្នាំ |

កំណត់សំគាល់ :

-ក្នុងថ្នាក់នីមួយៗ បើប្រវត្តិរូបមន្ត្រីនោះស្ថិតក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ថ្នាក់

-មន្ត្រីដែលមានអតីតភាពការងារតិចជាង ៨ ឆ្នាំ ក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ ត្រូវដាក់អោយស្ថិតក្នុង ថ្នាក់លេខ ១០ ទោះបីប្រវត្តិរូបស្ថិតក្នុងកាំទី ២ ក៏ដោយ ។

**មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិក្រមការ មាន ÷**

-អនុប្រធានការិយាល័យ នៃមន្ទីរខេត្តក្រុង សាលាខេត្តក្រុង និងថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

| ឋានន្តរស័ក្តិក្រមការ | អតីតភាពបំរើការងាររដ្ឋ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | |
| ថ្នាក់លេខ ៦ | ២៤ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៧ | ២១ - ២៤ ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៨ - ២១ ឆ្នាំ |
| ថ្នាក់លេខ ៩ | ១៥ - ១៨ ឆ្នាំ |
| ថ្នាក់លេខ ១០ | ១២ - ១៥ ឆ្នាំ |
| ថ្នាក់លេខ ១១ | ៩ - ១២ ឆ្នាំ |
| ថ្នាក់លេខ ១២ | ៦ - ៩ ឆ្នាំ |
| ថ្នាក់លេខ ១៣ | ៣ - ៦ ឆ្នាំ |
| ថ្នាក់លេខ ១៤ | ក្រោម ៣ ឆ្នាំ |

**កំណត់សំគាល់ :**

-ក្នុងថ្នាក់នីមួយៗ បើបៀវត្សមន្ត្រីនោះស្ថិត ក្នុងកាំទី ២ ត្រូវបន្ថែមអោយ ១ថ្នាក់ ។

ឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យលេខ ...៨៨...អនក្រ..បក..ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០១

## គោលការណ៍សមាហរណកម្មទៅតាមប្រភេទការបៀវត្សចូលក្នុងក្របខ័ណ្ឌប្រភេទ ក

| ឋានន្តរស័ក្តិ និងថ្នាក់ | បៀវត្សបច្ចុប្បន្ន ប្រភេទ ខ I | ផ្សេងៗ |
|---|---|---|
| ឋានន្តរស័ក្តិទី ១ | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ឋានន្តរស័ក្តិទី ២ | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | | |
| ថ្នាក់លេខ ១០ | | |
| ឋានន្តរស័ក្តិទី ៣ | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | ខ I.៦ | |
| ថ្នាក់លេខ ១០ | ខ I.៥ | |
| ថ្នាក់លេខ ១១ | ខ I.៤ | |
| ថ្នាក់លេខ ១២ | ខ I.៣ | |
| ថ្នាក់លេខ ១៣ | ខ I.២ | |
| ថ្នាក់លេខ ១៤ | ខ I.១ | |

## គោលការណ៍សមាហរណកម្មទៅតាមប្រភេទកាំបៀវត្សចូលក្នុងក្របខ័ណ្ឌប្រភេទ ខ

| ឋានន្តរស័ក្តិ និងថ្នាក់ | បៀវត្សបច្ចុប្បន្ន ប្រភេទ ខ II | ផ្សេងៗ |
|---|---|---|
| **ឋានន្តរស័ក្តិទី ១** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| **ឋានន្តរស័ក្តិទី ២** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | | |
| ថ្នាក់លេខ ១០ | | |
| **ឋានន្តរស័ក្តិទី ៣** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | ខ II.៦ | |
| ថ្នាក់លេខ ១០ | ខ II.៥ | |
| ថ្នាក់លេខ ១១ | ខ II.៤ | |
| ថ្នាក់លេខ ១២ | ខ II.៣ | |
| ថ្នាក់លេខ ១៣ | ខ II.២ | |
| ថ្នាក់លេខ ១៤ | ខ II.១ | |

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី ........ ខែ ........ ឆ្នាំ ........

| ឋានន្តរស័ក្តិ និងថ្នាក់ | បៀវត្សបច្ចុប្បន្ន | | | ផ្សេងៗ |
|---|---|---|---|---|
| | ប្រភេទ ខ III | ប្រភេទ គ I | ប្រភេទ ក II.១១ | |
| **ឋានន្តរស័ក្តិទី ១** | | | | |
| ថ្នាក់លេខ ១ | | | | |
| ថ្នាក់លេខ ២ | | | | |
| ថ្នាក់លេខ ៣ | | | | |
| ថ្នាក់លេខ ៤ | | | | |
| ថ្នាក់លេខ ៥ | | | ក II.១១.២ | |
| ថ្នាក់លេខ ៦ | | | ក II.១១.១ | |
| **ឋានន្តរស័ក្តិទី ២** | | | | |
| ថ្នាក់លេខ ១ | | | | |
| ថ្នាក់លេខ ២ | | | | |
| ថ្នាក់លេខ ៣ | | | | |
| ថ្នាក់លេខ ៤ | | | | |
| ថ្នាក់លេខ ៥ | | | | |
| ថ្នាក់លេខ ៦ | | | | |
| ថ្នាក់លេខ ៧ | | | | |
| ថ្នាក់លេខ ៨ | | | | |
| ថ្នាក់លេខ ៩ | | | | |
| ថ្នាក់លេខ ១០ | | | | |
| **ឋានន្តរស័ក្តិទី ៣** | | | | |
| ថ្នាក់លេខ ១ | | | | |
| ថ្នាក់លេខ ២ | | | | |
| ថ្នាក់លេខ ៣ | | | | |
| ថ្នាក់លេខ ៤ | | | | |
| ថ្នាក់លេខ ៥ | | | | |
| ថ្នាក់លេខ ៦ | | | | |
| ថ្នាក់លេខ ៧ | | គ I.៦ | | |
| ថ្នាក់លេខ ៨ | | គ I.៥ | | |
| ថ្នាក់លេខ ៩ | ខ III.៦ | គ I.៤ | | |
| ថ្នាក់លេខ ១០ | ខ III.៥ | គ I.៣ | | |
| ថ្នាក់លេខ ១១ | ខ III.៤ | គ I.២ | | |
| ថ្នាក់លេខ ១២ | ខ III.៣ | គ I.១ | | |
| ថ្នាក់លេខ ១៣ | ខ III.២ | | | |
| ថ្នាក់លេខ ១៤ | ខ III.១ | | | |

## គោលការណ៍សមាហរណកម្មទៅតាមប្រភេទការបៀវត្សចូលក្នុងប្រភេទ ឃ

| ឋានន្តរស័ក្តិ និងថ្នាក់ | បៀវត្សបច្ចុប្បន្ន | | | | ផ្សេងៗ |
|---|---|---|---|---|---|
| | ប្រភេទ គ IV | ប្រភេទ គ III | ប្រភេទ គ II | ប្រភេទ ខ IV | |
| **ឋានន្តរស័ក្តិទី ១** | | | | | |
| ថ្នាក់លេខ ១ | | | | | |
| ថ្នាក់លេខ ២ | | | | | |
| ថ្នាក់លេខ ៣ | | | | | |
| ថ្នាក់លេខ ៤ | | | | | |
| ថ្នាក់លេខ ៥ | | | | | |
| ថ្នាក់លេខ ៦ | | | | | |
| **ឋានន្តរស័ក្តិទី ២** | | | | | |
| ថ្នាក់លេខ ១ | | | | | |
| ថ្នាក់លេខ ២ | | | | | |
| ថ្នាក់លេខ ៣ | | | | | |
| ថ្នាក់លេខ ៤ | | | | | |
| ថ្នាក់លេខ ៥ | | | | | |
| ថ្នាក់លេខ ៦ | | | | | |
| ថ្នាក់លេខ ៧ | | | | | |
| ថ្នាក់លេខ ៨ | | | | | |
| ថ្នាក់លេខ ៩ | | | | | |
| ថ្នាក់លេខ ១០ | | | | | |
| **ឋានន្តរស័ក្តិទី ៣** | | | | | |
| ថ្នាក់លេខ ១ | | | | | |
| ថ្នាក់លេខ ២ | | | | | |
| ថ្នាក់លេខ ៣ | | | | | |
| ថ្នាក់លេខ ៤ | | | | | |
| ថ្នាក់លេខ ៥ | | | | | |
| ថ្នាក់លេខ ៦ | | | គ II.៦ | | |
| ថ្នាក់លេខ ៧ | | គ III.៦ | គ II.៥ | | |
| ថ្នាក់លេខ ៨ | | គ III.៥ | គ II.៤ | ខ IV.៦ | |
| ថ្នាក់លេខ ៩ | គ IV.៦ | គ III.៤ | គ II.៣ | ខ IV.៥ | |
| ថ្នាក់លេខ ១០ | គ IV.៥ | គ III.៣ | គ II.២ | ខ IV.៤ | |
| ថ្នាក់លេខ ១១ | គ IV.៤ | គ III.២ | គ II.១ | ខ IV.៣ | |
| ថ្នាក់លេខ ១២ | គ IV.៣ | គ III.១ | | ខ IV.២ | |
| ថ្នាក់លេខ ១៣ | គ IV.២ | | | ខ IV.១ | |
| ថ្នាក់លេខ ១៤ | គ IV.១ | | | | |

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៩ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦ / អនក្រ.បក / ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើត ខុទ្ទកាល័យនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

### សំរេច

**មាត្រា ១** : បង្កើត «ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ» ហៅកាត់ថា «ក.ប.ស» នៅអមខុទ្ទកាល័យនាយករដ្ឋមន្ត្រី ។

**មាត្រា ២** : សមាសភាព និងរចនាសម្ព័ន្ធ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រួមមាន ÷

- ប្រធាន និងអនុប្រធាន ក.ប.ស ត្រូវមានសមត្ថភាពខាងផ្នែកចំណេះវិជ្ជា និងនៅក្នុងការបំពេញការងារពិសេសគឺការងារពាក់ព័ន្ធនឹងការវិភាគ និងការរៀបចំចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។
- សមាជិកយ៉ាងតិចប្រាំរូប ដែលត្រូវមានគុណសម្បត្តិ ចំណេះវិជ្ជា និងបទពិសោធន៍ការងារក្នុងវិស័យណាមួយនៃមុខជំនាញសេដ្ឋកិច្ច ហិរញ្ញវត្ថុ នីតិសាស្ត្រ ពាណិជ្ជកម្ម កសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ឬ ឧស្សាហកម្ម ។
- មានអគ្គលេខាធិការមួយរូប សំរាប់ជាជំនួយអោយប្រធាន និងអនុប្រធាន ក.ប.ស នៅក្នុងការបំពេញការងារប្រចាំថ្ងៃ ។
- សមាជិក ក.ប.ស នីមួយៗ អាចមានមន្ត្រីជំនួយការផ្នែកស្រាវជ្រាវ និងវិភាគគោលនយោបាយចំនួនពីររូប ដែលត្រូវមានសមត្ថភាពខាងផ្នែកចំណេះដឹងយ៉ាងហោចចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើង ។

- ប្រធានកិត្តិយស ក.ប.ស មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។
- ប្រធាន ក.ប.ស មានឋានៈស្មើ រដ្ឋមន្ត្រី ។
- អនុប្រធាន ក.ប.ស មានឋានៈស្មើ រដ្ឋមន្ត្រី ។
- អគ្គលេខាធិការ ក.ប.ស មានឋានៈស្មើ រដ្ឋលេខាធិការ ។
- សមាជិក ក.ប.ស អាចមានឋានៈស្មើ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ។
- មន្ត្រីជំនួយការស្រាវជ្រាវ និងវិភាគគោលនយោបាយ អាចមានឋានៈស្មើ អគ្គនាយក អគ្គនាយករង ឬ ប្រធាននាយកដ្ឋាន ។
- ប្រធានកិត្តិយស ប្រធាន អនុប្រធាន សមាជិក អគ្គលេខាធិការ និងមន្ត្រីជំនួយការស្រាវជ្រាវ និងវិភាគគោលនយោបាយ នៃ ក.ប.ស ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងអនុក្រឹត្យ ។

**មាត្រា ៣**: ក.ប.ស មានប្រធានកិត្តិយសម្នាក់ ដែលជ្រើសរើសពីក្នុងចំណោមឥស្សរជន ដែលមានគុណសម្បត្តិក្នុងការបំរើប្រទេសជាតិ មានបទពិសោធន៍ខ្ពស់ និងមានការទទួលស្គាល់នៅក្នុងមជ្ឈដ្ឋានជាតិ និងនៅលើឆាកអន្តរជាតិ ។

**មាត្រា ៤**: ភារកិច្ច និងមុខងារសំខាន់ៗរបស់ ក.ប.ស មានដូចតទៅ÷

- ពិនិត្យ និងរៀបចំឯកសារ និងសុន្ទរកថាសំខាន់ៗនានា ព្រមទាំងលើកឡើងគំនិតផ្តួចផ្តើមទាំងឡាយ ដែលមានចរិតជាចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រកែទំរង់ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិជូនប្រមុខរាជរដ្ឋាភិបាល ។
- ធ្វើជាសេនាធិការអោយនាយករដ្ឋមន្ត្រី នៅក្នុងការតាមដាន និងបូកសរុបការអនុវត្តន៍ការងារកែទំរង់ និងគំនិតផ្តួចផ្តើមនានាក្នុងផ្នែកសេដ្ឋកិច្ច ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញផ្ទាល់ ។
- ធ្វើជាសេនាធិការអោយនាយករដ្ឋមន្ត្រី នៅក្នុងការតាមដាន និងបូកសរុបរបាយការណ៍នានា ដែលពាក់ព័ន្ធនឹងការអនុវត្តន៍ផែនការប្រាំឆ្នាំ និងកម្មវិធីអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ព្រមទាំងផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីធានាអោយបាននូវសង្គតភាពនៅក្នុងគោលនយោបាយសេដ្ឋកិច្ចជាតិ ព្រមទាំងដើម្បីតំរង់ទិស និងបង្កើនល្បឿននៃការអនុវត្តន៍ផែនការ និងកម្មវិធីទាំងនោះ ។
- រៀបចំអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល សំដៅធានាអោយបាននូវគុណភាព និងសង្គតភាព នៃគោលនយោបាយសេដ្ឋកិច្ចជាតិ នៅក្នុង និងរវាងវិស័យនានា និងផ្តល់យោបល់ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីដាក់ចេញនូវទិសដៅច្បាស់លាស់ សំរាប់ការអនុវត្តន៍ដោយរលូននូវគោលនយោបាយ និងយុទ្ធសាស្ត្រនៃផែនការប្រាំឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ ។
- ស្នើឡើងនូវវិធានការជាក់ស្តែងនានា ក្នុងទិសដៅកែលំអការគ្រប់គ្រងសេដ្ឋកិច្ចជាតិ និងពង្រឹងអភិបាលកិច្ចល្អជូននាយករដ្ឋមន្ត្រីពិនិត្យ និងសំរេច ។
- បូកសរុប និងធ្វើរបាយការណ៍សង្ខេបជូនប្រមុខរាជរដ្ឋាភិបាលជ្រាប អំពីស្ថានការណ៍សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ ហើយផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសំរបសំរួលដំណើរការនយោបាយសេដ្ឋកិច្ចជាតិ អោយស្របទៅតាមនិន្នាការវិវត្តន៍នៃសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ ។
- រៀបចំអោយមានជំនួបរវាង ក.ប.ស ជាមួយនាយករដ្ឋមន្ត្រី ដើម្បីទទួលបាននូវការវាយតម្លៃ និងការណែនាំនៅក្នុងទិសដៅធ្វើការកែលំអចាំបាច់នូវការងាររបស់ ក.ប.ស ។

**មាត្រា ៥ :** ដើម្បីអាចបំពេញមុខងាររបស់ខ្លួន ដូចមានចែងក្នុងមាត្រា ៤ ខាងលើ ជូនប្រមុខរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ ក.ប.ស ត្រូវមានតំណាងចូលរួមតាមដាននៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី និងអង្គប្រជុំអន្តរក្រសួងផ្សេងៗ ដែលរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី និងដោយក្រសួង- ស្ថាប័ននានា នៅក្នុងទិសដៅសំរបសំរួលការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការកែទំរង់នានារបស់រាជរដ្ឋាភិបាល ។ គ្រប់ក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធទាំងអស់ របស់រាជរដ្ឋាភិបាលមានភារកិច្ចផ្តល់នូវឯកសារ ពត៌មាន និងកិច្ចសហការចាំបាច់នានាជូនដល់ ក.ប.ស ។

**មាត្រា ៦ :** ក.ប.ស បើកការប្រជុំរបស់ខ្លួនទៅតាមតម្រូវការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន និងតាមសេចក្តីបង្គាប់របស់នាយករដ្ឋមន្ត្រី ។

**មាត្រា ៧ :** ក.ប.ស ប្រើប្រាស់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី នៅក្នុងក្របខ័ណ្ឌនៃថវិកាខុទ្ទកាល័យនាយករដ្ឋមន្ត្រី ។ ក.ប.ស មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពជំនួយបរទេស និងពីប្រភពផ្សេងៗទៀត សំរាប់ចំណាយលើសេវារដ្ឋបាល និងសំរាប់បំរើសេចក្តីត្រូវការក្នុងការផ្គត់ផ្គង់សំភារៈ បរិក្ខារ និងប្រាក់ឧបត្ថម្ភផ្សេងៗ តាមការកំណត់នៅក្នុងគោលដៅធ្វើអោយកាន់តែប្រសើរឡើងនៃការអនុវត្តមុខងាររបស់ខ្លួន ។

**មាត្រា ៨ :** ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ។

**មាត្រា ៩ :** អនុក្រឹត្យលេខ ០១/អនក្រ.បក/ ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១០:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ...... ខែ កញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩០ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការផ្ទេរឥណទានថវិកា**

************

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ . ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**<u>សំរេច</u>**

<u>មាត្រា១</u>: ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ២០០ លានរៀល ( ពីររយលានរៀល ) ពីជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច ) របស់ក្រសួងអប់រំ យុវជន និង កីឡា " ផ្នែក ឧត្តមសិក្សា "សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ឥណទានថវិកា ក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ សំរាប់ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ២០០១

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤០១...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំង និងផ្ទេរភារកិច្ចនាយនគរបាលជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំង និងផ្ទេរភារកិច្ចនាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ÷

១- ឧត្តមសេនីយ៍ត្រី ហ៊ីង ឆន អត្តលេខ ០០៣០ បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋានកណ្តាលនគរបាលព្រំដែន ជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន នៃក្រសួងមហាផ្ទៃ

២- ឧត្តមសេនីយ៍ត្រី ឡៅ ស៊ិនប៉ា អត្តលេខ ០១២៥ បច្ចុប្បន្នប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ ជាប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក នៃក្រសួងមហាផ្ទៃ

៣- ឧត្តមសេនីយ៍ត្រី ចាន់ វាសនា អត្តលេខ ០២៤៦ បច្ចុប្បន្នប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក ជាប្រធាននាយកដ្ឋាន សណ្តាប់ធ្នាប់ នៃក្រសួងមហាផ្ទៃ

៤- ឧត្តមសេនីយ៍ត្រី សួន វ៉ត្ថសារ៉ាយ អត្តលេខ ០០២៩ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ជាអនុប្រធានទី ១ នាយកដ្ឋាននគរបាលព្រំដែនគោក នៃក្រសួងមហាផ្ទៃ

៥- ឧត្តមសេនីយ៍ត្រី ប៉ូ លីដា អត្តលេខ ០០៦៩ បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ ជាប្រធាននាយកដ្ឋានមធ្យោបាយ នៃក្រសួងមហាផ្ទៃ

៦- ឧត្តមសេនីយ៍ត្រី ចៅ ឫទ្ធិសក្តិ អត្តលេខ ០០៨៧ បច្ចុប្បន្នប្រធាននាយកដ្ឋានសណ្ដាប់ធ្នាប់ ជាអនុប្រធានទី ១ នាយកដ្ឋានកណ្ដាលនគរបាលព្រំដែន នៃក្រសួងមហាផ្ទៃ

៧- វរសេនីយ៍ឯក សាយ ឡោ អត្តលេខ ០២៨៤ បច្ចុប្បន្នប្រធានស្ដីទីនាយកដ្ឋានសុខាភិបាល ជាប្រធាននាយកដ្ឋានសុខាភិបាល នៃក្រសួងមហាផ្ទៃ

៨- វរសេនីយ៍ឯក ហួរ ឡាយ អត្តលេខ ០៣៩៧ បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋានបុគ្គលិក ជាអនុប្រធានទី ១ នាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ នៃក្រសួងមហាផ្ទៃ

៩- វរសេនីយ៍ឯក សុខ សួស្តី អត្តលេខ ០០៧៦ បច្ចុប្បន្នអនុប្រធានទី១សេនាធិការដ្ឋាន ជានាយករងខុទ្ទកាល័យ នៃក្រសួងមហាផ្ទៃ

១០- វរសេនីយ៍ឯក យ៉ែម កឿង អត្តលេខ ០១១១ បច្ចុប្បន្នអនុប្រធានទី១ នាយកដ្ឋាននគរបាលព្រំដែនគោក ជាអនុប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ នៃក្រសួងមហាផ្ទៃ

១១- វរសេនីយ៍ឯក ថាវ គឹមហោ អត្តលេខ ០២៤៣ បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋានជនបរទេស ជាប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃក្រសួងមហាផ្ទៃ

១២- វរសេនីយ៍ឯក សួ តាំងឆាយ អត្តលេខ ០៧២៧ បច្ចុប្បន្នអនុប្រធាននគរបាលព្រហ្មទណ្ឌ ជាអនុប្រធានទី ១ នាយកដ្ឋានបុគ្គលិក នៃក្រសួងមហាផ្ទៃ

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គនាយកនគរបាលជាតិ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤០៧ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានផ្លាស់លោក **សុខ សោភ័ណ** បច្ចុប្បន្នទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង អោយមកបំរើការងារនៅក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**ចំលងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤០៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/ ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានតម្លើងមុខតំណែងរបស់លោក **ហោ មុនីរ័ត្ន** បច្ចុប្បន្នលេខាធិការទី១ស្ថានឯកអគ្គរាជទូតជាទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**ចំលងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤០៤ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៤ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានប្រគល់ **មេដាយមាសការងារ** ជូនមន្ត្រីក្រុមការងារត្រួតពិនិត្យអាណត្តិបើកប្រាក់ និងតារាងទូទាត់បៀវត្សរ៍ធ្វើដោយដៃ ជាមួយនឹងតារាងទូទាត់បៀវត្សរ៍តាមប្រព័ន្ធពត៌មានវិទ្យា ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើប្រទេសជាតិ ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ស៊ាន ទិសុទ្ធ** | សមាជិកអចិន្ត្រៃយ៍អង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ |
| ២- លោក | **ហង្ស ឆាំឆាន** | អគ្គនាយករងទទួលបន្ទុកតារាងបៀវត្សរ៍ |
| ៣- លោកវរៈសេនីយ៍ឯក | **ខួន ស្រេង** | តំណាងកងកម្លាំង នគរបាលជាតិកម្ពុជា |
| ៤- លោក | **កែវ ធីទុធ** | តំណាងលេខាធិការដ្ឋានអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ |

៥- លោកវរៈសេនីយ៍ទោ **ឌុយ ស៊ីម** តំណាងកងរាជអាវុធហត្ថជាតិ

៦- លោក **ឌី ចំរើន** តំណាងក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច

៧- លោក **ទៀង វដ្ឋា** តំណាងលេខាធិការដ្ឋានមុខងារសាធារណៈ

៨- លោក **ឆាយ សាវុធ** តំណាងលេខាធិការដ្ឋានអង្គភាពប្រឆាំងរាល់សកម្មភាព អំពើពុករលួយ

៩- លោក **គល់ សាមេត** តំណាងលេខាធិការដ្ឋានអង្គភាពប្រឆាំងរាល់សកម្មភាព អំពើពុករលួយ

១០- លោក **ឈុប សាម៉េត** តំណាងលេខាធិការដ្ឋានអង្គភាពប្រឆាំងរាល់សកម្មភាព អំពើពុករលួយ

១១- លោក **ជួប សុផាន** តំណាងក្រុមការងារជំរឿនមន្ត្រីរាជការស៊ីវិល

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិ-ការដ្ឋាន នៃក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ ✓

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤០៥ អនក្រ.តត

## អនុក្រឹត្យ

### ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ

~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

### ស ំ រ េ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈជូនចំពោះសព ÷

១-វរសេនីយ៍ទោ គង់ សំអឿន អត្តលេខ ០០១៥៩៩ នាយរងការិយាល័យចៅក្រមស៊ើបអង្កេត តុលាការយោធា

២-វរសេនីយ៍ទោ យូ ស៊ីនន អត្តលេខ ០០១២០០ នាយរងការិយាល័យហ្វឹកហ្វឺន ទីចាត់ការហ្វឹកហ្វឺន អគ្គបញ្ជាការដ្ឋាន

៣-វរសេនីយ៍ទោ គ្លីប គូន្សា អត្តលេខ ០០២០១២ មេបញ្ជាការរង និងជានាយសេនាធិការ កងរាជអាវុធហត្ថខេត្តកំពង់ឆ្នាំង

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា២
ឯកសារ-កាលប្បវត្តិ
~~~~~~

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤០៦ អនក្រ.ធក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមក្នុងការកសាងអាគារសិក្សា ០១ ខ្នង បីជាន់ មាន ១៥ បន្ទប់ បំពាក់សំភារៈសិក្សាគ្រប់បន្ទប់ ជួយកសាងបង្គន់អនាម័យ ០១ខ្នង មាន ២០បន្ទប់ និងចាក់ដីលុបស្រះពីមុខអាគារ ៥.០០០ម៣ នៅក្នុងអនុវិទ្យាល័យ កូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់សរុប ចំនួន ១៣៥.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ :

១-លោក **អ៊ុន សុវណ្ណ**

២-លោកស្រី **ហង្ស ស៊ីនួន**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨០៧ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ចំនួន ០៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមក្នុងការកសាង ក្លោងទ្វារ និងរបងសាលាបឋមសិក្សា រោងគោ ស្រុកមង្គលបូរី ទិញអង្ករ ចំនួន ២០ តោន ចែកជូនប្រជាជន ១.៣០០ គ្រួសារ នៅក្នុងឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ និងធ្វើអំណោយគ្រែ ចំនួន ១០០ ព្រមទាំងសំភារៈសំរាប់អ្នកជម្ងឺ ជូនមន្ទីរពេទ្យខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :

**ក-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោកឧកញ៉ា **ធាន ឡឿន** ហៅ គោគ ថវិកា ចំនួន ៧.០០០ ដុល្លារអាមេរិក

២-លោក **យឿន ផន** ថវិកា ចំនួន ៥.១០០ ដុល្លារអាមេរិក

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោកជំទាវ **អ៊ុច ថៃ** ថវិការួមជាមួយលោកឧកញ៉ា **ធាន ឡឿន**

២-លោក **នួន ជេច** អ្នកស្រី **ខុប លឿម** ថវិកាចំនួន ១.៦១៥ ដុល្លារអាមេរិក

៣-លោក គាន់ សំអុល ថវិកាចំនួន ១.៦១៥ ដុល្លារអាមេរិក

៤-លោក ឆាយ ឆាត់ ថវិកាចំនួន ១.១៦០ ដុល្លារអាមេរិក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និងមាត្រា ២
-រាជកិច្ច
-កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៤០៨ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកឧកញ៉ា **ស៊ិន សុខណា** អគ្គនាយករងក្រុមហ៊ុន សូគីម៉ិច ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអាគារសិក្សា ០៣ ខ្នង មាន ១៥ បន្ទប់ និង តុសិស្ស នៅអនុវិទ្យាល័យបាភ្នំ ស្រុកបាភ្នំ សាលាបឋមសិក្សាជោរ ស្រុកកំចាយមារ ខេត្តព្រៃវែង និង អនុវិទ្យាល័យ ស ខេង ថ្នល់កែង ព្រមទាំងផ្តល់រថយន្ត TOYOTA Pick Up ០១ គ្រឿង និង ម៉ូតូ ០៣ គ្រឿង ដល់កំលាំងនគរបាលជាតិ ចំណាយអស់ទឹកប្រាក់សរុបចំនួន ១០៩.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យឯកឧត្តម ស ខេង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៨ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤២ ស.ស.ណ

ភ្នំពេញ,ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០០១

**សូមទូលថ្វាយ**

**សម្តេចក្រុមព្រះប្រធានរដ្ឋសភា**

**កម្មវត្ថុ** : សំណើសុំជួយធ្វើអន្តរាគមន៍ ទៅក្រសួងពាក់ព័ន្ធអំពីករណីព្រំដែនកម្ពុជា-វៀតណាម ដែលបានបោះបង្គោលចូលក្នុងទឹកដីកម្ពុជា ជំរៅ២០គីឡូម៉ែត្រ នៅក្នុងខេត្តស្វាយរៀង ។

**យោង** : លិខិតរបស់សម្តេចក្រុមព្រះប្រធានរដ្ឋសភា លេខ៥២៨រស ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០១ ។

**សម្តេចក្រុមព្រះជាទីសក្ការៈដ៏ខ្ពង់ខ្ពស់**

តាមកម្មវត្ថុ និងយោងខាងលើ ទូលព្រះបង្គំមានកិត្តិយសសូមទូលថ្វាយថា របាយការណ៍ដែលតំណាងរាស្ត្រ នឹង ស៊ិន រាយការណ៍ថ្វាយព្រះអង្គថា ក្នុងឱកាសចុះត្រួតពិនិត្យសួរសុខទុក្ខប្រជារាស្ត្រដែលរស់នៅតាមច្រកអូរ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ឥឡូវនេះមានទុក្ខលំបាកដោយមិនបានធ្វើស្រែចំការលើដីស្រែដែលនៅអមទាំងពីរសងខាងអូរនោះ ដោយវៀតណាមមិនអនុញ្ញាត ។ តាមរបាយការណ៍នេះដែរ ករណីចម្លែកនេះបណ្តាលមកពី "វៀតណាមបានជិះទូកតាមអូរមួយ ចូលយ៉ាងជ្រៅប្រហែល២០គីឡូម៉ែត្រ ក្នុងដីខ្មែរ ហើយនៅចុងអូរដែលមិនអាចជិះទូកទៅមុខទៀតរួច គេក៏បោះបង្គោលខ័ណ្ឌសីមា ដែលគេដាំមានចារិក ឆ្នាំ១៩៨៧ នៅទីនោះតែម្តង កំណត់ថាអូរ ឬព្រែកនោះជាដែនទឹករបស់គេ " ។

បន្ទាប់ពីបានទទួលរបាយការណ៍របស់តំណាងរាស្ត្រ នឹង ស៊ិន មក ក្រុមការងារនៃគណៈកម្មាធិការចំរុះកិច្ចការព្រំដែន ដឹកនាំដោយលោក វ៉ា គឹមហុង និងមានការចូលរួមពីអាជ្ញាធរដែនដី តំណាងដោយអភិបាលខេត្តស្វាយរៀង បានចុះត្រួតពិនិត្យនៅថ្ងៃទី១៧ សីហា ឆ្នាំ២០០១ ដើម្បីរកការពិត ថាតើបង្គោលលេខ "ញ១" បោះចូល២០គីឡូម៉ែត្រក្នុងដីខ្មែរមែនឬអត់ ដូចដែលតំណាងរាស្ត្រ នឹង ស៊ិន បានអះអាង ។

លទ្ធផលនៃការចុះត្រួតពិនិត្យ ដោយប្រើម៉ាស៊ីន GPS Explorer III ដែលមានការជាក់លាក់តិចជាង១០ម៉ែត្រនោះ បានបញ្ជាក់ឱ្យដឹងថា :

១-បង្គោល **"ញ១"** បោះត្រូវតាមទីតាំងតាមផែនទីអមសន្ធិសញ្ញា ឆ្នាំ១៩៨៥ ខ្នាត១/១០០ ០០០ បោះពុម្ពឆ្នាំ១៩៥៤ដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ដែលមានលក្ខណៈសមស្របនិងផែនទីតំកល់ទុកនៅអ.ស.បឆ្នាំ១៩៦៤ដែរ ។ ទីតាំងបង្គោល **"ញ១"** បច្ចុប្បន្ន បានទទួលរងនូវការហូរច្រោះដី ដែលអាចបណ្តាលឱ្យបង្គោលនេះស្រុត ឬទ្រេតបាន ។

២-ទីតាំងបង្គោល **"ឈ១២-២"** ដែលបោះនៅចំកណ្តាលវាលស្រែ ជាប្រភេទបង្គោលតូច តពីបង្គោល **"ញ១"** មក ហើយបង្គោលនេះតាមការពិនិត្យដោយម៉ាស៊ីន GPS Explorer III ទីតាំងរបស់វាស្ថិតចូលក្នុងទឹកដីវៀតណាម ចំងាយប្រហែល៦០ម៉ែត្រ បើប្រៀបធៀបៈទានិងផែនទីអមសន្ធិសញ្ញាឆ្នាំ១៩៨៥ ខ្នាត១/៥០ ០០០ ។ <u>*បច្ចុប្បន្នប្រជាពលរដ្ឋខ្មែរ បានធ្វើស្រែទាំងសងខាងខ្សែព្រំដែនក្នុងតំបន់នេះ ផ្ទុយពីការអះអាងរបស់តំណាងរាស្ត្រ នឹង ស៊ិន*</u> ។

ការអះអាងរបស់តំណាងរាស្ត្រ នឹង ស៊ិន ពុំមានមូលដ្ឋានអ្វីទាល់តែសោះ ហើយជាការបញ្ជាក់ថា តំណាងរាស្ត្ររូបនេះ មិនស្គាល់ទាំងភូមិសាស្ត្រស្រុកកំពង់រោទិ៍ផង ព្រោះថាបង្គោល **"ញ១"** បោះនៅឆ្នាំ១៩៨៧ ពុំមែនជាបង្គោលបោះដោយចៃដន្យ ដូចការអះអាងនោះទេ តែជាបង្គោលបោះដោយគណៈកម្មការចំរុះព្រំដែនកម្ពុជា-វៀតណាម ដែលមានឯកសារកំណត់ហេតុត្រឹមត្រូវតាមផែនទីក្រុមភូមិសាស្ត្រឥណ្ឌូចិន ដែលកម្ពុជាបានដាក់នៅអង្គការសហប្រជាជាតិ នៅឆ្នាំ១៩៦៤ ដែលជាផែនទីឧបសម្ព័ន្ធសន្ធិសញ្ញាឆ្នាំ១៩៨៥ ។

សូមជូនភ្ជាប់មកជាមួយ នូវផែនទីទីតាំងបង្គោល **"ញ១"** និង **"ឈ១២-២"** នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

សូមសម្តេចក្រុមព្រះប្រធានរដ្ឋសភា មេត្តាទទួលនូវសេចក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីទូលព្រះបង្គំ ។

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន:</u>

-ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-ឯកឧត្តម ហោ ណាំហុង ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម វ៉ា គឹមហុង ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៦៦ សហវ.......

ទីស្តីការគណៈរដ្ឋមន្ត្រី
មកដល់ ថ្ងៃទី 11 ខែ ... ឆ្នាំ ...
ម៉ោង 14h45 លេខ ...

# ប្រកាស

## ស្តីពី

## ការកំណត់ពន្ធនាំចូលជាបន្ទុករបស់រដ្ឋ លើការនាំចូលទំនិញជាវត្ថុធាតុដើម សំរាប់ផលិតឱសថ

~~~~

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០១
- យោងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០០១ លើលិខិតលេខ ១៩៤៨ /០១ ក.អ.ក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
~~~~

## **សំរេច**

**ប្រការ ១** : ត្រូវបានកំណត់ជាបន្ទុករបស់រដ្ឋនូវពន្ធនាំចូលលើទំនិញមួយចំនួនដែលជាវត្ថុធាតុដើម សំរាប់ផលិតឱសថដែលមានការបញ្ជាក់ទទួលស្គាល់ និងអនុញ្ញាតពីក្រសួងសុខាភិបាលជាមុន ។

**ប្រការ ២** : ពន្ធនាំចូលលើទំនិញដូចមានចែងក្នុងប្រការ ១ ខាងលើ ដែលរដ្ឋទទួលបន្ទុក ត្រូវបានកត់ត្រាបូកសរុបជាចំណូលនៃថវិកាប្រចាំខែ ហើយត្រូវបានកត់ត្រាក្នុងចំណាយជាអន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋ " ជំពូក ៣០ " ។

**ប្រការ ៣** : បទបញ្ញត្តិដែលមានពីមុនមក និងមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤** : អគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច និងប្រធាននាយកដ្ឋានដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០១

**គាត ឈន់**

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត - ក្រុង

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៤ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន
លេខ : ៣៤៤ ប្រក.សក.ពក

ភ្នំពេញ ថ្ងៃទី 31 ខែ 8 ឆ្នាំ ២០០១

ជំនួយការគណៈរដ្ឋមន្ត្រី
មកដល់ថ្ងៃទី 07 ខែ 9 ឆ្នាំ 2001
ម៉ោង 15 ... លេខ 281

# ប្រកាស

## ស្តីអំពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់មន្ទីរ សាធារណការនិងដឹកជញ្ជូន ខេត្ត- ក្រុង

## រដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០.១១.១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤.០១.១៩៩៦ ស្តីពីការបង្កើតក្រសួង សាធារណការ និង ដឹកជញ្ជូន ។

-បានឃើញ អនុក្រឹត្យលេខ ១៤/អនក្រ.បក ចុះថ្ងៃទី ០៣.០៣.១៩៩៨ ស្តីពីរៀបចំនិងការប្រព្រឹត្តិទៅរបស់ ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

-យោងតាមការចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ ១ :** ប្រកាសនេះកំណត់អំពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អង្គភាពមូលដ្ឋាន ចំណុះក្រសួងសាធារណការ និងដឹកជញ្ជូន ហៅថា " មន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្ត-ក្រុង " ដែលមានភារកិច្ច ជាអាទិ៍ :

-តំណាងអោយស្ថាប័នក្រសួង លើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល អំពីវិស័យ សាធារណការ និង ដឹកជញ្ជូន នៅមូលដ្ឋានខេត្ត-ក្រុង ។

-គ្រប់គ្រងលើផ្នែករដ្ឋបាល និង រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្ស មន្ត្រី-រាជការក្រោមឱវាទ ។

-គ្រប់គ្រងត្រួតពិនិត្យការដឹកជញ្ជូន គ្រប់ប្រភេទ រាប់ទាំងមធ្យោបាយដឹកជញ្ជូន ទីចំណត និងការដ្ឋានជួសជុល កែច្នៃ តម្លើងមធ្យោបាយដឹកជញ្ជូនទាំងនោះ តាមការកំណត់របស់ក្រសួង ។

-គ្រប់គ្រងថែរក្សារាល់សមិទ្ធិ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជាអាទិ៍ ផ្លូវថ្នល់ ស្ពាន កំពង់ផែ ( លើកលែងតែកំពង់ផែស្វយ័តក្រុងភ្នំពេញ និង កំពង់ផែស្វយ័តក្រុងព្រះសីហនុ ) ព្រលានយន្តហោះ ប្រពន្ធ័លូ ... ស្ថានីយចម្រោះទឹកកខ្វក់ កំពង់ដរ អាគារ ជីឡូ ស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

-គ្រប់គ្រង ថែរក្សា អនាម័យសាធារណៈ ក្នុងខេត្ត-ក្រុង តាមដងផ្លូវជាតិ និង ផ្លូវខេត្តនានា ។

-ស្រាវជ្រាវលើកគំរោងផែនការអភិវឌ្ឍន៍ លើវិស័យសាធារណការនិងដឹកជញ្ជូន នៅមូលដ្ឋានខេត្ត-ក្រុង

**ប្រការ ២ :** មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្ត-ក្រុង ដឹកនាំដោយ នាយក មន្ទីរម្នាក់ អមដោយ នាយករង មួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**ប្រការ ៣ :** រចនាសម្ព័ន្ធដឹកនាំ និង គ្រប់គ្រង មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង រួមមាន :

ក/ **ការិយាល័យកណ្ដាលរបស់មន្ទីរ :**

- ការិយាល័យ រដ្ឋបាល បុគ្គលិក
- ការិយាល័យ ផែនការ គណនេយ្យ
- ការិយាល័យ សាធារណការ
- ការិយាល័យ ដឹកជញ្ជូន

ខ/ **អង្គភាពក្រោមឱវាទមន្ទីរ :**

- អង្គភាពគ្រឿងចក្រ
- អង្គភាពស្ពានថ្នល់
- អង្គភាពរបើសក្រុង
- អង្គភាព ជលមាគ៌ា និង កំពង់ផែ
- អង្គភាព អគ្គីសនីបំភ្លឺសាធារណៈ
- អង្គភាពសួនច្បារ រុក្ខជាតិ
- អង្គភាពសំអាតទីក្រុង
- អង្គភាពគ្រប់គ្រង លូទឹក និង ស្ថានីយ៍ចម្រោះទឹកស្អុយ

គ/ **ការិយាល័យសាធារណការ និងដឹកជញ្ជូន ខ័ណ្ឌ - ស្រុក :**

**ប្រការ ៤ :** ការកំណត់ចំនួនអង្គភាពក្រោមឱវាទមន្ទីរ ដែលចែងក្នុងប្រការ ៣ ចំណុច " ខ " ខាងលើ អាស្រ័យដោយ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង ពិនិត្យ សុំយោបល់ពីក្រសួង តាមភូមិសាស្ត្រ និងតម្រូវការអភិវឌ្ឍន៍របស់មូលដ្ឋានជាក់ស្ដែង ។

**ប្រការ ៥ :** ការិយាល័យនីមួយៗដឹកនាំដោយ នាយការិយាល័យមួយរូប និង អមដោយនាយរងការិយាល័យមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

អង្គភាពនិមួយៗ ដឹកនាំដោយប្រធានមួយរូប និង អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អង្គភាពចំណុះមន្ទីរ សមមូលថ្នាក់ការិយាល័យកណ្ដាល នៃ មន្ទីរនានាជុំវិញខេត្ត-ក្រុង ។

**ប្រការ ៦ :** មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង និមួយ ៗ មានភារកិច្ចរៀបចំរចនាសម្ពន្ធ័ និងការប្រព្រឹត្តិទៅរបស់មន្ទីរ ដោយផ្អែកលើ (ព)នូវតួនាទីភារកិច្ច របស់ថ្នាក់ការិយាល័យ អង្គភាព ជូនក្រសួងពិនិត្យសំរេច ។

**ប្រការ ៧ :** ប្រកាសនេះ នឹង ត្រូវធ្វើនិយ័តកម្ម តាមអនុក្រឹត្យនៅពេលខាងក្រោយ ។

**ប្រការ ៨ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩:** នាយកខុទ្ទកាល័យ , អគ្គនាយក នៃ អគ្គនាយកដ្ឋានរដ្ឋបាល , អគ្គនាយក នៃ អគ្គនាយកដ្ឋានសាធារណការ អគ្គនាយក នៃ អគ្គនាយកដ្ឋានដឹកជញ្ជូន , អគ្គាធិការ នៃ អគ្គាធិការដ្ឋាន និង នាយកមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួនតាម ខ្លឹមសារនៃប្រកាសនេះ ដែលមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការមុខងារសាធារណៈ
- សាលា ខេត្ត-ក្រុង

**ដើម្បីជូនជ្រាបជាព័ត៌មាន**

- ដូចប្រការ ៩
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- គ្រប់មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត-ក្រុង

**ដើម្បីអនុវត្ត**

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ឃី តាំងលឹម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ២១៤ បទ.ប្រក

ភ្នំពេញ,ថ្ងៃទី០៣, ខែកញ្ញា ឆ្នាំ២០០១

ទីស្ដីការគណៈរដ្ឋមន្ត្រី
មកដល់ថ្ងៃទី 17 ខែ 9 ឆ្នាំ២០០១
ម៉ោង 15.10 លេខ 288

# ប្រកាស

## ស្ដីពី

## ការតម្លើងកាំប្រាក់បៀវត្សរ៍ជូនមន្ត្រី បុគ្គលិករាជការ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញលិខិតលេខ ២០៦មស.បវ ចុះថ្ងៃទី២៩-០៣-១៩៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងប្រកាសលេខ ១៤៥ បទ.ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ ស្ដីពីការបង្កើតគណៈកម្មការរៀបចំតម្លើងកាំថ្នាក់មន្ត្រីរាជការ សំរាប់ឆ្នាំ ២០០០
- យោងកំណត់ហេតុស្ដីពីការតម្លើងកាំថ្នាក់មន្ត្រីរាជការសំរាប់ឆ្នាំ២០០០
- ពិនិត្យសមត្ថភាពជំនាញបច្ចេកទេស អតីតភាព របស់មន្ត្រីរាជការ

# សំរេច

**ប្រការ១:** តម្លើងកាំប្រាក់ ជូនមន្ត្រីរាជការ បំរើការងារនៅក្រសួង និងនៅតាមបណ្តាមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្ត-ក្រុង ចំនួន ៣៩៤នាក់ ។

**ប្រការ២:** ផ្តល់ខ្ទង់ប្រាក់បៀវត្សថ្មីជូនមន្ត្រីរាជការខាងលើ ចាប់ពីថ្ងៃទី១៣-០៤-២០០០ តទៅ ។

**ប្រការ៣:** ខុទ្ទកាល័យ,អធិការដ្ឋាន,នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញវត្ថុ,មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ គ្រប់ខេត្ត-ក្រុង និងសាម៉ីខ្លួនទាំង ៣៩៤នាក់ខាងលើត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះ ។

**ប្រការ៤:** ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃដូចមានចែងក្នុងប្រការ ២ ខាងលើ ។

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
-ដូចប្រការ៣ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រី

ស៊ូន-ឆ្មឿន

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពត៌មាន**
**MINISTRY OF INFORMATION**

រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០១

លេខ ២៣៤/ ព.ម ប្រ-ក

ទីស្តីការគណៈរដ្ឋមន្ត្រី
មកដល់ថ្ងៃទី 05 ខែ 9 ឆ្នាំ 2001
ម៉ោង 10.15 លេខ 278

# ប្រកាស
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨.៧២ ចុះថ្ងៃទី៣០.១១.១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស.រកម ០១៩៦.១៤ ចុះថ្ងៃទី២៤.០១.១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី០៥.០៨.១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងប្រកាសលេខ២៦៣/០០ ព.ម.ប្រ.ក ចុះថ្ងៃទី ០៦-០៩-២០០០ របស់ក្រសួងពត៌មាន
- យោងលិខិតស្នើសុំប្តូរនាយកគ្រប់គ្រង ចុះថ្ងៃទី៣១.០៨.២០០១ របស់អ្នកស្រី SIEW NYOKE CHOW

## សំរេច

**ប្រការ១:** អនុញ្ញាតអោយអ្នកស្រី SIEW NYOKE CHOW ជំនួស លោក ទិត ងួន បន្តបើកអាជីវកម្មរោងពុម្ពឈ្មោះ "CAMBODIA SIN CHEW DAILY" ដែលមានទីតាំងស្ថិតនៅផ្ទះសំណង់ថ្មី ផ្លូវលេខ ២០០៥ សង្កាត់កាកាប ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

**ប្រការ២:** រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របតាមទំនៀមទំលាប់ប្រពៃណីខ្មែរ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៣:** ក្នុងករណីប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងប្រការ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

**ប្រការ៤:** នាយកដ្ឋានសោតទស្សន៍ នៃក្រសួងពត៌មាន មន្ទីរពត៌មានរាជធានីភ្នំពេញ សាមីខ្លួន និងអាជ្ញាធរ ដែលពាក់ព័ន្ធត្រូវទទួលអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ៥:** ប្រកាសនេះមានសុពលភាព រយៈពេល១ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

ល. ល្បូសម្ពូ

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាក្រុងភ្នំពេញ "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានសោតទស្សន៍ នៃក្រសួងពត៌មាន
- មន្ទីរពត៌មានរាជធានីភ្នំពេញ "ដើម្បីអនុវត្ត"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**

លេខ ...... ក.ព

ទីស្តីការគណៈរដ្ឋមន្ត្រី
មកដល់ថ្ងៃទី ...
ម៉ោង ... លេខ ...

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០១

# ប្រកាស

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រ.ក.ត/១១៩៨/៧២ ចុះថ្ងៃ ទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃ ទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៨៩៥-០៧ ចុះថ្ងៃ ទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ច្បាប់ស្តីពីរបបសារព័ត៌មាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃ ទី៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ ក្រសួងព័ត៌មាន ។
- បានឃើញលិខិតរបស់លោកកញ្ញា ឃុន រដ្ឋា ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីសំណើសុំច្បាប់អនុញ្ញាតបោះពុម្ពផ្សាយសារព័ត៌មាន "នរិខ្មែរ" ។

### សម្រេច

**ប្រការ១ :** អនុញ្ញាតឱ្យសារព័ត៌មាន "នរិខ្មែរ" ដំណើរការបោះពុម្ពចែកផ្សាយដោយមានកញ្ញា ឃុន រដ្ឋា ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការ ផ្ទះលេខ ៨អ៊ីអ៊ីស្ទន្យ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ក្រុងភ្នំពេញ ។

**ប្រការ២ :** រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារព័ត៌មាន ក្រមសីលធម៌អ្នកសារព័ត៌មាន ។

**ប្រការ៣ :** ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ ២ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៤ :** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផ្សព្វផ្សាយព័ត៌មាននៃក្រសួងព័ត៌មាន និង ចាងហ្វាងសារព័ត៌មាន "នរិខ្មែរ" ត្រូវអនុវត្តន៍ប្រកាសនេះ ។

**ប្រការ៥ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ ។ ក្នុងករណីពុំមានសុំបន្តអាយុកាលនៃអាជ្ញាប័ណ្ណក្រោយរយៈពេលពីរខែ ក្រសួងព័ត៌មានចាត់ទុកថា សារព័ត៌មាននេះនឹងបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកទេសរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- តុលាការរាជធានីភ្នំពេញ
- អភិបាលរាជធានីភ្នំពេញ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

[illegible]

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF INFORMATION

**ក្រសួងពត៌មាន**

លេខ...៤៣៧/០១.......ពម ព្រ-ត

ភ្នំពេញ,ថ្ងៃទី០៤ ខែកញ្ញាឆ្នាំ ២០០១

ទីស្ដីការគណៈរដ្ឋមន្ត្រី
មកដល់ ថ្ងៃទី០៤ ខែ ៩ ឆ្នាំ ២០០១
ម៉ោង 15.10 លេខ 284

# ប្រកាស
## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការបង្កើតក្រសួងពត៌មាន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ច្បាប់ស្ដីពីរបបសារពត៌មាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពត៌មាន ។
- បានឃើញលិខិតរបស់លោក ម៉ុក ចន្ទ័តារា ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០១ ស្ដីពីសំណើសុំច្បាប់បោះពុម្ពផ្សាយទស្សនាវដ្ដី ឈ្មោះ " **កម្ពុជាមរតក** " ។

## សម្រេច

**ប្រការ១ :** អនុញ្ញាតឱ្យទស្សនាវដ្ដី " **កម្ពុជាមរតក** " ដំណើរការបោះពុម្ពចែកផ្សាយដោយមានលោក **ម៉ុក ចន្ទ័តារា** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការ ផ្ទះលេខ ២៦៧អីអង ផ្លូវលេខ ១៦៣ សង្កាត់ទួលទំពូង២ រាជធានីភ្នំពេញ ។

**ប្រការ២:** រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាច្បាប់ស្ដីពីរបបសារពត៌មានក្រមសីលធម៌អ្នកសារពត៌មាន ។

**ប្រការ៣ :** ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ ២ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៤ :** អគ្គនាយករដ្ឋបាល និង សោតទស្សន៍ ប្រធាននាយកដ្ឋានមជ្ឈមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងចាងហ្វាងការផ្សាយទស្សនាវដ្ដី " **កម្ពុជាមរតក** " ត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ៥ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាល នៃអាជ្ញាប័ណ្ណលើសរយៈពេល ៣ខែ ក្រសួងពត៌មានចាត់ទុកថាសារពត៌មាននេះបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

**ចម្លងជូន**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេធាវីរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- តុលាការរាជធានីភ្នំពេញ
- អភិបាលរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមន៍សារពត៌មាន
- "ផ្ទីប្រជាសតិមាន"

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

លី. ធីយុយ៉ង